# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៧ សសរ

## សេចក្តីសំរេច

## ស្តីពីការផ្ទេរសិទ្ធិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចលេខ៦៦សសរ ចុះថ្ងៃទី០២ខែវិច្ឆិកាឆ្នាំ២០០១ ស្តីពីការផ្ទេរសិទ្ធិនៃរាជរដ្ឋាភិបាល
- យោងតាមសំណូមពរតារងារចាំបាច់របស់រាជរដ្ឋាភិបាល

### សំរេច

ប្រការ ១ : ផ្ទេរសិទ្ធិជូនឯកឧត្តម ឆាយ ថន រដ្ឋមន្ត្រីក្រសួងផែនការជារដ្ឋមន្ត្រីស្តីទីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ជំនួសឯកឧត្តម អ៊ឹម ឈុនលឹម ដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រថៃឡង់ដ៍ ចាប់ពីថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០០១ រហូតដល់ពេលឯកឧត្តម អ៊ឹម ឈុនលឹម អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម ឆាយ ថន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែ វិច្ឆិកា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រីស្តីទី

ឆាយ ថន

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com